**មាត្រា ២ ..** ស្រុកម៉ាឡៃ ត្រូវស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលរបស់ខេត្តបន្ទាយមានជ័យ ។

**មាត្រា ៣ ..** ស្រុកម៉ាឡៃ ត្រូវបានបង្កើតឃុំចំនួន ០៥ ចំណុះ គឺ ឃុំទួលពង្រ ឃុំអូរសំព័រ ឃុំអូរស្រឡៅ ឃុំម៉ាឡៃ និងឃុំបឹងបេង ។

**មាត្រា ៤ ..** ស្រុកម៉ាឡៃ ត្រូវបានកំណត់ព្រំប្រទល់រដ្ឋបាលដូចខាងក្រោម :

- ខាងជើងទល់និងព្រំប្រទល់ស្រុកអូរជ្រៅ នៃខេត្តបន្ទាយមានជ័យ និងព្រំប្រទល់ព្រះរាជាណាចក្រថៃឡង់ដ៍ ។
- ខាងត្បូងទល់នឹងព្រំប្រទល់ស្រុកសំពៅលូន នៃខេត្តបាត់ដំបង ។
- ខាងកើតទល់នឹងព្រំប្រទល់ស្រុកមង្គលបូរី នៃខេត្តបន្ទាយមានជ័យ ។
- ខាងលិចទល់នឹងព្រំប្រទល់ ព្រះរាជាណាចក្រថៃឡង់ដ៍ ។

**មាត្រា ៥ ..** ទីតាំងសាលាស្រុកម៉ាឡៃ ស្ថិតនៅក្នុងឃុំម៉ាឡៃ ។

**មាត្រា ៦ ..** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧ ..** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋានត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

* * *

## អនុក្រឹត្យ លេខ ៤០ អនក្រ.បក

## ស្តីពីការបង្កើតស្រុកវាលវែង ចំណុះខេត្តពោធិ៍សាត់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស./រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ .-** ត្រូវបានបង្កើតស្រុកវាលវែង។

**មាត្រា ២ .-** ស្រុកវាលវែង ត្រូវស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលរបស់ខេត្តពោធិ៍សាត់ ។

**មាត្រា ៣ .-** ស្រុកវាលវែង ត្រូវបានបង្កើតឃុំចំនួន ០៥ ចំណុះ គឺ ឃុំអូរសោម ឃុំក្រពើពីរ ឃុំអន្លង់រាប ឃុំប្រម៉ោយ និងឃុំថ្មដា ។

**មាត្រា ៤ .-** ស្រុកវាលវែង ត្រូវបានកំណត់ព្រំប្រទល់រដ្ឋបាលដូចខាងក្រោម :

- ខាងជើងទល់នឹងព្រំប្រទល់ស្រុកមោងឫស្សី នៃខេត្តបាត់ដំបង និងស្រុកបាកាន ខេត្តពោធិ៍សាត់ ។
- ខាងត្បូងទល់នឹងព្រំប្រទល់ស្រុកថ្មបាំង នៃខេត្តកោះកុង ។
- ខាងកើតទល់នឹងព្រំប្រទល់ស្រុកភ្នំក្រវាញ នៃ ខេត្តពោធិ៍សាត់ ។
- ខាងលិចទល់នឹងព្រំប្រទល់ ស្រុកសំឡូត នៃខេត្តបាត់ដំបង និងព្រំប្រទល់ព្រះរាជាណាចក្រថៃឡង់ដ៏ ។

**មាត្រា ៥ .-** ទីតាំងសាលាស្រុកវាលវែង ស្ថិតនៅក្នុងឃុំប្រម៉ោយ ។

**មាត្រា ៦ .-** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧ .-** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋានត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

* * *